# ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបប្រតិភូអង្គភាពកម្មសិទ្ធិបញ្ញា នៃប្រទេសសឹង្ហបុរី



នៅរសៀលថ្ងៃទី ០៤ ខែមីនា ឆ្នាំ ២០១៥ ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម រួមជាមួយថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទក្រសួង បានទទួលជួបគណៈ ប្រតិភូអង្គភាពកម្មសិទ្ធិបញ្ញានៃប្រទេសសឹង្ហបុរី ដឹកនាំដោយលោក **Tan Yih San** ប្រធានអង្គភាពកម្មសិទ្ធិញ្ញានៃប្រទេសសឹង្ហបរី ដើម្បីពិភាក្សាការងារទាក់ទងការពង្រឹងកិច្ចសហប្រតិបត្តិការ ស្តីពីកម្មសិទ្ធិឧស្សាហកម្ម បន្ទាប់ពីភាគីទាំងពីរកម្ពុជា-សឹង្ហបុរី បានចុះអនុស្សារណៈយោគយល់គ្នាកាលពីថ្ងៃទី២០ ខែ មករា ឆ្នាំ២០១៥ ដោយប្រធានអង្គភាពទាំងពីរ នៅប្រទេសសឹង្ហបុរីកន្លងទៅនេះ ។

ក្នុងជំនួបពិភាក្សានោះ ភាគីទាំងពីរបានផ្លាស់ប្តូរទស្សនៈរួមមានៈ-ការអនុវត្តកិច្ចសហប្រតិបត្តិការផ្នែកកម្មសិទ្ធិឧស្សាហកម្ម ក្រោមអនុស្សារណៈយោគយល់គ្នារវាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាមយយអង្គភាពកម្មសិទ្ធីបញ្ញាសឹង្ហបុរី -ផ្លាស់ប្តូរទស្សនៈអំពីសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាក្នុងក្របខណ្ឌអាស៊ាន និងជាមួយអង្គភាពកម្មសិទ្ធិបញ្ញាពិភពលោក-ពិភាក្សាការអនុវត្តលើគម្រោងសហប្រតិបត្តិការកម្មសិទ្ធបញ្ញា ដែលមានចែងក្នុងអនុស្សារណៈយោគយល់គ្នាពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៧ ។







មានប្រសាសន៍នាឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានបញ្ជាក់ថា: នេះជាលទ្ធផលចាប់ផ្តើមនៃការអនុវត្តអនុស្សារណៈយោគយល់គ្នា លើកដំបូងរវាងអង្គភាពទាំងពីរ ដើម្បីជម្រុញកិច្ចការពារកម្មសិទ្ធិបញ្ញា ការអភិវឌ្ឍន៏បច្ចេកវិទ្យា និងការវិនិយោគរវាងទាំងពីរកម្ពុជា-សឹង្ហបុរិ ។ ដោយឡែកក្នុងក្របខណ្ឌអាស៊ាន ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានបង្ហាញនូវគំនិតផ្តួចផ្តើម ដើម្បីពិនិត្យលទ្ធភាព ធ្វើយ៉ាងណាឱ្យវិស័យការពារកម្មសិទ្ធិបញ្ញានេះមានវិសាលភាពរួមសម្រាប់ប្រទេសទាំង១០ ក្នុងអាស៊ាន ។ មានន័យថា បើក្រុមហ៊ុន ឯកជន រឺស្ថាប័នណាមួយ ចង់ចុះបញ្ជីការពារកម្មសិទ្ធបញ្ញារបស់ខ្លួន គឺអាចដាក់ពាក្យនៅប្រទេសណាមួយ រឺក៏អាចបង្កើតអង្គភាពរួមមួយ ដើម្បីទទួលពាក្យ

ធ្វើការវាយតម្លៃទទួលស្គាល់ សម្រាប់ប្រទេសអាស៊ានទាំង១០ តែម្តង ។ ដូច្នេះ យើងអាចពន្លឿនបានកាន់តែខ្លាំងនៃលំហូរវិនិយោគចូល ក្នុងតំបន់ និងលើកកំពស់កិច្ចការពារកម្មសិទ្ធិបញ្ញាជាទូទៅ ។





លោក **Tan Yih San** ប្រធានអង្គភាពកម្មសិទ្ធិបញ្ញា សឹង្ហបុរី និងសហការីចំនួន០២រូបទៀត គឺលោកបណ្ឌិត **Leong Hoi Liong** នាយកស្តីទីផ្នែកចុះបញ្ជីប្រកាសនីយបត្រតក្កកម្ម និងលោក បណ្ឌិត **Bernard Ong** ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃអង្គភាពកម្មសិទ្ធិបញ្ញាសឹង្ហបុរី បានវាយតម្លៃខ្ពស់ចំពោះកិច្ចពិភាក្សានាថ្ងៃនេះ ដោយបានលើកពីលទ្ធផលសម្រេចបាន និងផែនការសកម្មភាពការងារទៅថ្ងៃមុខ ។ ក្នុងនោះ ភាគីសឹង្ហបុរី បានស្វាគមន៍ចំពោះកិច្ចពិភាក្សាបន្ទាប់ទៀត ដែលបានកំណត់ឡើងនៅខែ សីហា ខាងមុខ នៅប្រទេសសឹង្ហបុរី ។

ក្នុងចុងជំនួបនៃកិច្ចពិភាក្សា ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** តំណាងភាគីកម្ពុជា បានផ្តល់វិញ្ញាបនបត្រ ប្រកាសនីយបត្រតកក្កកម្មដល់ លោកប្រធាន **Tan Yih San** តំណាងភាគីសឹង្ហបុរី ដែលបានដាក់ស្នើសុំលើកទី១ ដើម្បីជានិមិត្តរូបនៃការទទួលស្គាល់គ្នាទៅវិញទៅមក ខាងផ្នែកប្រកាសនីយបត្រតក្កកម្ម ។






TWG

